**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
លេខ៣៧៧៧/១៧ ព.ណ.......ក.ជ.

ភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្នុងនាមគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា៖ កម្ពុជានឹងទៅចូលរួមពិព័រណ៍ពាណិជ្ជកម្ម "AMBIENTE 2018" នៅទីក្រុង FRANKFURT ប្រទេសអាល្លឺម៉ង់ ដែលនឹងត្រូវរៀបចំឡើងរយៈពេល ០៥ថ្ងៃ ចាប់ពីថ្ងៃទី០៩-១៣ ខែកុម្ភៈ ឆ្នាំ២០១៨។ ពិព័រណ៍ពាណិជ្ជកម្មនេះ នឹងត្រូវប្រព្រឹត្តទៅនៅលើផ្ទៃដីពិព័រណ៍ទំហំ ៣០៨,០០០ម៉ែត្រការ៉េ ដោយមានអ្នកចូលរួមតាំងពិព័រណ៍ជាងបួនពាន់ក្រុមហ៊ុន មកពីបណ្តាប្រទេសផ្សេងគ្នាជាង ៩០ប្រទេស និងតែងតែមានអ្នកទស្សនាសរុបប្រមាណជាង ១៣ម៉ឺននាក់។ ពិព័រណ៍ពាណិជ្ជកម្មនេះ ជាវេទិកាប្រមូលផ្តុំដ៏ធំមួយនូវការដាក់តាំងបង្ហាញ និងផ្សព្វផ្សាយស្វែងរកដៃគូពាណិជ្ជកម្មទៅលើផលិតផលបច្ចេកវិទ្យា ផលិតផលសិប្បកម្ម ផលិតផលសូត្រ និងក្រណាត់ សហគ្រាសធុនតូច និងមធ្យម គ្រឿងចម្លាក់ គ្រឿងអលង្ការ វត្ថុអនុស្សាវរីយ៍ធ្វើដោយដៃ ផលិតផលប្រើប្រាស់ក្នុងផ្ទះ ផលិតផលប្រើប្រាស់ក្នុងភោជនីយដ្ឋាន និងសម្រាប់ធ្វើម្ហូបអាហារ និងផលិតផលប្រើប្រាស់ជាច្រើនមុខទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញពាណិជ្ជករ និងអាជីវករទាំងអស់ ដែលមានបំណងទៅចូលរួមពិព័រណ៍ពាណិជ្ជកម្ម "AMBIENTE 2018" ឬមានគម្រោងស្វែងរកដៃគូវិនិយោគ ឬត្រូវចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយអាល្លឺម៉ង់ ក៏ដូចជាជាមួយបណ្តាប្រទេសអឺរ៉ុបផ្សេងទៀត មេត្តាប្រញាប់មកបំពេញបែបបទ និងផ្ញើគម្រោងរបស់ខ្លួនមកអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ឱ្យបានមុនថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ ជាកំហិត។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនង៖ ០៨៦ ៣៣៣ ៩៣៣ ឬ ០៩៥ ៩២៩ ១៩២ ឬ ០១៧ ៥៥៥ ២៧៧
អាសយដ្ឋានអ៊ីម៉ែល៖ sorn_pitou@yahoo.com ឬ saraysm@yahoo.com ឬ
vitholt@yahoo.com

**សូមអរគុណ!**

Ministry of Commerce
N°3777.MOC.P.EA.

# KINGDOM OF CAMBODIA
**Nation - Religion - King**

Phnom Penh, August 11 , 2017

## Announcement

On behalf of the Cambodian Inter-Ministerial Committee for Participation in the World Expo and the International Trade Exhibitions, the Ministry of Commerce has the honor to inform the public that Cambodia will attend the "AMBIENTE 2018", to be organized for a period of five days starting from 09-13 February 2018 in Frankfurt, Germany. This trade fair will be organized in the space of 308,000sqm, with the participation of more than 4000 exhibitors from over 90 countries and always joined by 130,000 visitors. This trade fair was considered a mass platform of the exhibit displaying and a promoting event for business matching on the products of technology, handicrafts, silks and fabrics, SMEs, sculptures, jewelry, hand-made souvenirs, household appliances, kitchen appliances and many other consuming products.

In this regard, all relevant traders and businessmen who intend to participate in the "AMBIENTE 2018" or wish to find their investment partners or sign MOU with Germany as well as other European countries are requested to apply and submit their projects to General Directorate of Trade Promotion of the Ministry of Commerce no later than 31st October 2017.

For further information, please contact the Department of Exhibition Affairs, General Directorate of Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh, Cambodia.

Tel : 086 333 933 / 095 929 192 / 017 555 799
E-mail : sorn_pitou@yahoo.com / saraysin@yahoo.com / vitholt@yahoo.com

Thank you !